# សាលាភូមិន្ទរដ្ឋបាល

# ប្រព័ន្ធរដ្ឋបាលកម្ពុជា

## Cambodian Administrative System

រៀបរៀង និងបង្រៀនដោយ ចុីយ ធឿន
ជានាយករងសាលាភូមិន្ទរដ្ឋបាល ឆ្នាំ២០១៨

# មាតិកានៃការសិក្សា

-លំនាំដើមនៃប្រព័ន្ធរដ្ឋបាលកម្ពុជា

-មេរៀនទី១. គោលការណ៍នីត្យានុកូលនៃរបបរដ្ឋបាល

-មេរៀនទី២. រូបមន្តនៃការគ្រប់គ្រងរដ្ឋបាល

-មេរៀនទី៣. ការរៀបចំរដ្ឋបាលទូទៅ

-មេរៀនទី៤. គ្រឹះស្ថានសាធារណៈ

# លំនាំដើមនៃប្រព័ន្ធរដ្ឋបាលកម្ពុជា

- **អ្វីទៅជាប្រព័ន្ធរដ្ឋបាលកម្ពុជា?**

-តាមន័យនិរុត្តិសាស្ត្រខ្មែរ ពាក្យថា រដ្ឋបាល មានន័យថា ការគ្រប់គ្រង ឬ ការថែរក្សាប្រទេស នគរ បុរី។

-តាមអត្ថន័យជាទូទៅ៖ រដ្ឋបាល គឺជាដំណើរការនៃការរៀបចំចាត់ចែង ដោយមានរចនាសម្ព័ន្ធដឹកនាំ និងការសម្រេចជាប្រចាំ។

- ក្នុងន័យនេះ ប្រព័ន្ធរដ្ឋបាលកម្ពុជា សំដៅទៅលើសំណុំនៃអង្គ ដែលមាន រចនាសម្ព័ន្ធដឹកនាំ សម្រាប់ជានាលើដំណើរការនៃការរៀបចំចាត់ចែង កិច្ចការនានារបស់រដ្ឋ។

# មេរៀនទី១
# គោលការណ៍នីត្យានុកូលនៃរបបរដ្ឋបាល

- គោលការណ៍នីត្យានុកូលនៃរបបរដ្ឋបាល ជាគោលការណ៍មួយដែលកំណត់ឲ្យអាជ្ញាធររដ្ឋបាលអនុវត្តសកម្មភាពរបស់ខ្លួនស្របតាមវិធានច្បាប់។
- វាបានបង្កើតឲ្យមានរដ្ឋបាលមួយនៃនីតិរដ្ឋ។
- គោលការណ៍នីត្យានុកូលភាពនេះ ត្រូវបានផ្សារភ្ជាប់នូវកត្តា ដូចខាងក្រោម៖

  -ឋានានុក្រមនៃធម្មនិយាមគតិយុត្ត

  -វិធានអនុវត្តចំពោះរាជការ

  -អំណាចឆន្ទានុសិទ្ធិ

  -សមត្ថកិច្ចជាប់ចំណង

  -នីត្យានុកូលភាពនៃអញ្ញត្រកម្ម។

## ១-ឋានានុក្រមនៃធម្មនិយាមគតិយុត្ត

- គឺជាគោលការណ៍មួយ ដែលកំណត់ឲ្យអាជ្ញាធររដ្ឋបាលត្រូវដាក់ចេញសេចក្តីសម្រេចរដ្ឋបាល ឲ្យស្របទៅតាមលំដាប់នៃលិខិតបទដ្ឋាន។
- គោលការណ៍នេះ ត្រូវបានលោក Hans Kelsen លើកឡើងថា ច្បាប់ជាវិទ្យាសាស្ត្រមួយដែលមានក្បួនខ្នាតប្រទាក់ប្រទិនគ្នាពីលើមកក្រោមយ៉ាងមាំ ដោយមានរាងជាសាជីជ្រុង( Pyramid ) រួមមាន៖

-រដ្ឋធម្មនុញ្ញ

-សន្ធិសញ្ញា

-ច្បាប់

-បទបញ្ញា។

## ២-វិធានអនុវត្តចំពោះរាជការ

- គឺជាគោលការណ៍មួយ ដែលតម្រូវឲ្យរាជការអនុវត្តការងាររបស់ខ្លួន ដោយមានគោលដៅគិតគូពីផលប្រយោជន៍ទូទៅជាចម្បង។
- គោលការណ៍នេះ ត្រូវបានផ្សាភ្ជាប់នូវកត្តា ២យ៉ាង៖

  -មធ្យោបាយរបស់រាជការ មានបុព្វសិទ្ធិនៃអំណាចសាធារណៈ

  -វិធានដែលរាជការត្រូវប្រតិបត្តិក្នុងការងាររបស់ខ្លួន ដូចជា៖

    .ត្រូវមានច្បាប់សំអាង

    .ត្រូវយកវិធានទូទៅមានតម្លៃខ្ពស់ជាងវិធានពិសេស

    .មិនត្រូវបំពានវិធានដែលខ្លួនបានចេញ

    .ត្រូវគោរពបែបបទនិងសមត្ថកិច្ច

    .មិនត្រូវខុសខ្លឹមសារថ្នាក់លើទេ។

- **៣-អំណាចឆន្ទានុសិទ្ធិ**
- គឺជាគោលការណ៍មួយ ដែលផ្តល់សិទ្ធិអំណាចឱ្យអាជ្ញាធររដ្ឋបាលអាចធ្វើការសម្រេចកិច្ចការនានាដោយឆន្ទៈផ្ទាល់ខ្លួន។
- គោលការណ៍នេះ ត្រូវបានកត់សម្គាល់នូវកត្តា ២យ៉ាងដូចខាងក្រោម៖

-ជាសិទ្ធិអំណាច សម្រាប់ធានាការប្រព្រឹត្តទៅនៃការងារប្រចាំថ្ងៃរបស់រាជការ

-ជាសិទ្ធិអំណាច ក្នុងការសម្រេចដោយមិនចាំបាច់មានការយល់ព្រមពីតុលាការជាមុននោះទេ។

- **៤-សមត្ថកិច្ចជាប់ចំណាង**
- គឺជាគោលការណ៍មួយ ដែលកំណត់ឱ្យអាជ្ញាធររដ្ឋបាលត្រូវតែអនុវត្តសិទ្ធិអំណាចរបស់ខ្លួនចំពោះកិច្ចការនានាទៅតាមការកំណត់ដោយវិធានច្បាប់។
- គោលការណ៍នេះ បានចាប់បង្ខំអាជ្ញាធររដ្ឋបាល ដូចខាងក្រោម៖

  -ត្រូវធ្វើសម្រេចកិច្ចការនានានៅក្នុងក្របខ័ណ្ឌច្បាប់

  -គ្មានអំណាចសម្រេចបង្កើតលក្ខខណ្ឌបន្ថែម ក្រៅពីច្បាប់កំណត់នោះទេ។
- ដូច្នេះ រាជការត្រូវបម្រើប្រជាជន កាលបើពួកគាត់បានបំពេញគ្រប់គ្រាន់នូវលក្ខខណ្ឌដែលច្បាប់កំណត់។

- **៥-និត្យានុកូលភាពនៃអញ្ញត្រកម្ម**
- ជាគោលការណ៍ដែលអនុញ្ញាតឲ្យមានការលើកលែងចំពោះការអនុវត្តសមត្ថកិច្ចរបស់អាជ្ញាធររដ្ឋបាលតាមការកំណត់ដោយច្បាប់។
- អញ្ញត្រកម្មនៃអំពើរបស់អាជ្ញាធររដ្ឋបាល មានពីរយ៉ាងដូចខាងក្រោម៖

**-រដ្ឋាភិបាលកិច្ច៖** គឺសំដៅលើកិច្ចដែលជាលិខិតស្នាមរបស់រដ្ឋាភិបាល ពាក់ព័ន្ធទៅនឹងការគ្រប់គ្រងរដ្ឋបាលសាធារណៈនៅក្នុងរចនសម្ព័ន្ធ ទាំងក្នុងឧបរិរចនាសម្ព័ន្ធ ទាំងក្នុងហេដ្ឋារចនាសម្ព័ន្ធ ដែលមានក្នុងរដ្ឋាភិបាលមួយ( ទម្រង់ )។

**-កាលៈទេសៈពិសេស៖** គឺសំដៅទៅលើស្ថានភាពវិបត្តិដ៏ធំណាមួយ ដែលគំរាមកំហែងដល់ផលប្រយោជន៍ជាតិ ឬដល់និរន្តរភាពនៃដំណើរការរដ្ឋបាលសាធារណៈ នាំឲ្យអាជ្ញាធររដ្ឋបាលពុំចាំបាច់ពឹងផ្អែកលើវិធានច្បាប់ក្នុងការទប់ទល់នោះឡើយ។

កាលៈទេសៈពិសេស រួមមាន៖ សង្គ្រាម, ព្រឹត្តិការណ៍ចលាចលមានទ្រង់ទ្រាយធំ និងមហន្តរាយធម្មជាតិ។

# មេរៀនទី២
# រូបមន្តនៃការគ្រប់គ្រងរដ្ឋបាល

- ការគ្រប់គ្រងរដ្ឋបាលទូទៅអាចប្រើប្រាស់នូវរូបមន្តណាមួយដូចជា៖

-មជ្ឈការ

-វិសហមជ្ឈការ

-វិមជ្ឈការ

-សហត្ថិភាពរវាងវិមជ្ឈការនិងវិសហមជ្ឈការ។

- **១-ការគ្រប់គ្រងរដ្ឋបាលតាមបែបមជ្ឈការ**
- គឺជាប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលមួយប្រភេទ ដែលអាជ្ញាធររដ្ឋបាលកណ្ដាល មានសិទ្ធិអំណាចដោយផ្ទាល់ក្នុងការសម្រេចលើគ្រប់កិច្ចការរដ្ឋបាល(អំណាចមានលក្ខណៈប្រមូលផ្ដុំ)។



## ២-ការគ្រប់គ្រងរដ្ឋបាលតាមបែបវិសហមជ្ឈការ

- គឺជាបច្ចេកទេសនៃការគ្រប់គ្រងរដ្ឋបាលមួយប្រភេទដែលអាជ្ញាធររដ្ឋបាលកណ្តាលប្រគល់សិទ្ធិអំណាចឲ្យអាជ្ញាធរមូលដ្ឋានក្នុងការសម្រេចលើកិច្ចការរដ្ឋបាលមួយចំនួនតាមរយៈបទបញ្ជា(អំណាចមានលក្ខណៈបែង)។



- **៣-ការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ**
- គឺជាប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលមួយប្រភេទ ដែលអាជ្ញាធររដ្ឋបាលកណ្តាលផ្ទេរសិទ្ធិអំណាចឲ្យអាជ្ញាធរមូលដ្ឋានក្នុងការសម្រេចលើកិច្ចការរដ្ឋបាលនានាដោយមានចែងក្នុងច្បាប់(អំណាចមានលក្ខណៈផ្ទេរ)។



## ៤-សហត្ថិភាពរវាងវិមជ្ឈការនិងវិសហមជ្ឈការ

- គឺជាបច្ចេកទេសនៃការគ្រប់គ្រងរដ្ឋបាលមួយប្រភេទ ដែលអនុវត្តលាយបញ្ចូលគ្នារវាងប្រព័ន្ធវិមជ្ឈការនិងវិសហមជ្ឈការ ដើម្បីជួយដោះស្រាយឲ្យគ្នាទៅវិញទៅមកនូវគុណវិបត្តិនៃរូបមន្តនីមួយៗ(អំណាចមានលក្ខណៈសម្របសម្រួល )។



# មេរៀនទី៣
# ការរៀបចំរដ្ឋបាលទូទៅ

- អង្គរដ្ឋបាលទូទៅ ត្រូវបានរៀបចំជា ពីរ កម្រិតដូចជា៖

-រដ្ឋបាលថ្នាក់ជាតិ(រដ្ឋបាលកណ្តាល)

-រដ្ឋបាលថ្នាក់ក្រោមជាតិ(រដ្ឋបាលមូលដ្ឋាន)។

## ១-រដ្ឋបាលថ្នាក់ជាតិ (រដ្ឋបាលកណ្តាល)

- រដ្ឋបាលថ្នាក់ជាតិ ជាអង្គរដ្ឋបាលដែលប្រមូលផ្តុំនូវអាជ្ញាធររួមចូលគ្នានៃអំណាចនីតិប្រតិបត្តិ ដែលទទួលបន្ទុករៀបចំ និងដឹកនាំប្រទេស។
- វាត្រូវបានកំណត់ឲ្យមានអង្គរដ្ឋបាល ពីរលំដាប់ដូចជា៖

    -ព្រះមហាក្សត្រ

    -រាជរដ្ឋាភិបាល។

## ១.១-ព្រះមហាក្សត្រ

- ព្រះមហាក្សត្រជាអាជ្ញាធររដ្ឋបាលមួយខ្ពស់បំផុត ក្នុងឋានៈជាព្រះប្រមុខរដ្ឋ។
- តាមមាត្រា៧នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ចែងថា ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់គ្រងរាជសម្បត្តិ ប៉ុន្តែទ្រង់មិនកាន់អំណាចឡើយ។
- បញ្ញត្តិមាត្រា៧នេះ បានហាមឃាត់ចំពោះព្រះមហាក្សត្រក្នុងការអនុវត្តអំណាចផ្នែកនយោបាយ។
- ទន្ទឹមនឹងនេះ រដ្ឋធម្មនុញ្ញក៏បានផ្តល់ឲ្យទ្រង់នូវអំណាចផ្នែករដ្ឋបាលលើកិច្ចការមួយចំនួន ដូចខាងក្រោម៖

-ព្រះមហាក្សត្រទ្រង់តែងតាំងនាយករដ្ឋមន្ត្រី និងទ្រង់តែងតាំងគណៈរដ្ឋមន្ត្រីទាំងមូល។

## ១.១-ព្រះមហាក្សត្រ (ត)

-តាមសេចក្តីស្នើរបស់គណៈរដ្ឋមន្ត្រី ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តែងតាំង ផ្លាស់ប្តូរ ឬបញ្ចប់ភារកិច្ចមន្ត្រីជាន់ខ្ពស់ស៊ីវិលនិងយោធា ឯកអគ្គរាជទូត និងប្រេសិតវិសាមញ្ញ និងពេញសមត្ថភាព។

-តាមសេចក្តីស្នើរបស់ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យ តែងតាំង ផ្លាស់ប្តូរ ឬដកហូតចៅក្រមផ្នែកយុត្តាធិការ។

-ទ្រង់ជាមេបញ្ជាការកំពូលនៃកងយោធពលខេមរភូមិន្ទ។

-ទ្រង់គង់ជាព្រះអធិបតីនៃឧត្តមក្រុមប្រឹក្សាការពារជាតិ។

-ទ្រង់មានព្រះរាជសិទ្ធិបន្ធូរបន្ថយទោស និងលើកលែងទោស។

-ឧត្តមប្រឹក្សានៃអង្គចៅក្រម ស្ថិតក្រោមព្រះរាជាធិបតីភាពនៃព្រះមហាក្សត្រ។

-ទ្រង់ទទួលសារតាំងឯកអគ្គរាជទូត ឬឯកអគ្គរដ្ឋទូត និងប្រេសិតវិសាមញ្ញនិងពេញសមត្ថភាពនៃប្រទេសក្រៅ មកប្រចាំព្រះរាជាណាចក្រកម្ពុជា។

## ១.១-ព្រះមហាក្សត្រ (តចប់)

-ទ្រង់ឡាយព្រះហស្តលេខាលើសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិ ហើយទ្រង់ប្រទានសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាទាំងនោះ ក្រោយពីបានទទួលការអនុម័តយល់ព្រមពីរដ្ឋសភានិងព្រឹទ្ធសភា។

-ព្រះមហាក្សត្រទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រមប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ ច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់រួចហើយ។

-ព្រះមហាក្សត្រត្រូវរំលាយរដ្ឋសភា ក្រោយពីព្រះអង្គទ្រង់បានទទួលការស្នើពីនាយករដ្ឋមន្ត្រីនិងបន្ទាប់ពីទ្រង់បានការយល់ព្រមពីប្រធានរដ្ឋសភា។

-សមាជិកព្រឹទ្ធសភាចំនួន២រូប ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ។

-ទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ។

-ទ្រង់ប្រកាសសង្គ្រាមក្រោយការអនុម័តរបស់រដ្ឋសភា និងព្រឹទ្ធសភា។

-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ចំនួន៣រូប ត្រូវតែងតាំងដោយព្រះមហាក្សត្រ។

## ១.២-រាជរដ្ឋាភិបាល

- រាជរដ្ឋាភិបាល ជាអង្គការនីតិប្រតិបត្តិ មានសមត្ថកិច្ចកំណត់និងអនុវត្តនយោបាយរបស់រដ្ឋ ស្របតាមគោលការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ។
- រាជរដ្ឋាភិបាល ដឹកនាំកិច្ចការទូទៅរបស់រដ្ឋ ស្របតាមកម្មវិធីនយោបាយរបស់ខ្លួន។
- រាជរដ្ឋាភិបាល ត្រូវបានកំណត់នូវលំដាប់រដ្ឋបាល ដូចជា៖

  - គណៈរដ្ឋមន្ត្រី
  - ទីស្តីការគណៈរដ្ឋមន្ត្រី
  - ក្រសួង និងរដ្ឋលេខាធិការដ្ឋាន។

## ១.២-រាជរដ្ឋាភិបាល (ត)

**+ គណៈរដ្ឋមន្ត្រី**

- តាមមាត្រា១១៨ថ្មី(មួយ)នៃរដ្ឋធម្មនុញ្ញ ចែងថា គណៈរដ្ឋមន្ត្រីជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

-គណៈរដ្ឋមន្ត្រីត្រូវបានដឹកនាំដោយនាយករដ្ឋមន្ត្រី១រូប អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រី ជាសមាជិក។

-អង្គប្រជុំរបស់គណៈរដ្ឋមន្ត្រី មានអង្គប្រជុំធំ និងអង្គប្រជុំពិនិត្យស្រាវជ្រាវ។

-អង្គប្រជុំធំគឺជាកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យនិងសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាល។

-អង្គប្រជុំធំត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី។ នាយករដ្ឋមន្ត្រីអាចប្រគល់ភារកិច្ចជូនឧបនាយករដ្ឋមន្ត្រីដឹកនាំអង្គប្រជុំពិនិត្យស្រាវជ្រាវបាន។

## ១.២-រាជរដ្ឋាភិបាល (ត)

- គណៈរដ្ឋមន្ត្រី មានមុខងារដូចខាងក្រោម៖

-ចូលរួមរាយការណ៍ទូលថ្វាយព្រះមហាក្សត្រ ទ្រង់ជ្រាបអំពីសភាពការណ៍របស់ប្រទេសជាតិ ពីរដងក្នុង១ខែជាមួយនាយករដ្ឋមន្ត្រី។

-លើកសំណើទៅព្រះមហាក្សត្រឲ្យទ្រង់តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ តួនាទីមន្ត្រីជាន់ខ្ពស់ស៊ីវិលនិងយោធា ទេសាភិបាលនិងទេសាភិបាលរងធនាគារជាតិនៃកម្ពុជា ឯកអគ្គរាជទូត ប្រេសិតវិសាមញ្ញនិងពេញសមត្ថភាព។

-លើកសំណើទៅព្រះមហាក្សត្រ ឲ្យទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រម ដែលប្រកាសឱ្យប្រើច្បាប់។

-លើកសំណើទៅព្រះមហាក្សត្រឲ្យទ្រង់បង្កើត និងប្រទានគ្រឿងឥស្សរិយយសជាតិ។

-ពិនិត្យ និងសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាល។

## ១.២-រាជរដ្ឋាភិបាល (ត)

- ទន្ទឹមនឹងនេះ នាយករដ្ឋមន្ត្រី ដែលជាប្រមុខរាជរដ្ឋាភិបាល មានសមត្ថកិច្ចដូចខាងក្រោម៖

-ដឹកនាំ បញ្ជារាល់សកម្មភាពការងាររបស់រាជរដ្ឋាភិបាល។

-ដឹកនាំការងាររបស់គណៈរដ្ឋមន្ត្រី និងកោះប្រជុំនិងធ្វើជាអធិបតីនៃកិច្ចប្រជុំពេញអង្គរបស់គណៈរដ្ឋមន្ត្រី។ រដ្ឋធម្មនុញ្ញបានអនុញ្ញាតឱ្យនាយករដ្ឋមន្ត្រីរំលែកអំណាចរបស់ខ្លួនឱ្យទៅសមាជិកនៃរាជរដ្ឋាភិបាលណាម្នាក់ក៏បាន(មាត្រា១២៤)។

-អំណាចចេញបទបញ្ជា ដើម្បីណែនាំដល់មន្ត្រីក្រោមឱវាទ, សាធារណជន និងដើម្បីរក្សាសណ្តាប់ធ្នាប់សាធារណៈ ក្នុងករណី ឬស្ថានភាពជាក់ស្តែងណាមួយដែលគ្មានច្បាប់ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានគតិយុត្តណាមួយបានចែង។

-ដឹកនាំការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងនានា។

## ១.២-រាជរដ្ឋាភិបាល (ត)

-លើកសំណើថ្វាយព្រះមហាក្សត្រ ឲ្យទ្រង់តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចដោយព្រះរាជក្រឹត្យនូវមុខតំណែងមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិននៃកងយោធពលខេមរភូមិន្ទ និងមន្ត្រីនគរបាលជាតិ ដូចខាងក្រោម៖

.ទេសាភិបាល, ទេសាភិបាលរងធនាគារជាតិនៃកម្ពុជា

.អគ្គលេខាធិការក្រសួង អគ្គនាយកក្រសួង ឬមុខតំណែងប្រហាក់ប្រហែល

.អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត

.ឯកអគ្គរាជទូត ឬមុខតំណែងប្រហាក់ប្រហែល

.ប្រេសិតវិសាមញ្ញនិងពេញសមត្ថភាព

.អគ្គមេបញ្ជាការ អគ្គមេបញ្ជាការរង និងនាយសេនាធិការចម្រុះនៃកងយោធពលខេមរភូមិន្ទ

.អគ្គស្នងការនគរបាលជាតិ ។

-អំណាចតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច ដោយអនុក្រឹត្យនូវមន្ត្រីជាន់ខ្ពស់ស៊ីវិល យោធិន នគរបាលជាតិ ដូចជា៖ អគ្គនាយករង អភិបាលរងរាជធានីខេត្ត អភិបាលក្រុងស្រុកខណ្ឌ ប្រធាននាយកដ្ឋាន វរៈសេនីយ៍ឯក និងថ្នាក់ប្រហាក់ប្រហែល។

- **១.២-រាជរដ្ឋាភិបាល (ត)**

-មានសិទ្ធិស្នើសុំឲ្យមានការពិនិត្យធម្មនុញ្ញភាព និងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញ។

-ស្នើសុំទៅព្រះមហាក្សត្រឱ្យទ្រង់រំលាយរដ្ឋសភា បន្ទាប់ពីមានការទម្លាក់រាជរដ្ឋាភិបាលពីរដង ក្នុងរយៈពេល១២ខែ។

-អាចស្នើសុំឲ្យរដ្ឋសភាប្រជុំជាវិសាមញ្ញ។

-មានសិទ្ធិផ្តួចផ្តើមគំនិតធ្វើច្បាប់។

-មានអំណាចក្នុងការចូលរួមជ្រើសរើសព្រះមហាក្សត្រ(សមាជិកក្រុមប្រឹក្សារាជសម្បត្តិ)។

- នាយករដ្ឋមន្ត្រីមានអង្គភាពជំនួយការមួយ គឺ"**ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី**"។

## ១.២-រាជរដ្ឋាភិបាល (ត)

### +ទីស្ដីការគណៈរដ្ឋមន្ត្រី

- ទីស្ដីការគណៈរដ្ឋមន្ត្រីត្រូវបានបង្កើតឡើងដើម្បីធ្វើជាសេនាធិការជូនរាជរដ្ឋាភិបាល សម្រាប់សម្របសម្រួលការងារប្រចាំថ្ងៃរបស់គណៈរដ្ឋមន្ត្រី ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី។
- រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី មានតួនាទីគ្រប់គ្រង និងចាត់ចែងការងារទីស្ដីការគណៈរដ្ឋមន្ត្រី។
- ទីស្ដីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់។
- ទីស្ដីការគណៈរដ្ឋមន្ត្រីមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ទីស្ដីការគណៈរដ្ឋមន្ត្រី។

- តាមអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី បានកំណត់ឲ្យទីស្តីការគណៈរដ្ឋមន្ត្រី មានរចនាសម្ព័ន្ធចំណុះ ដូចជា៖

១-ខុទ្ទកាល័យ

២-អគ្គនាយកដ្ឋាន

-អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ

-អគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការទូទៅ

-អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

-អគ្គនាយកដ្ឋានសម្របសម្រួលកិច្ចការផ្ទៃក្នុង

-អគ្គនាយកដ្ឋានសេដ្ឋកិច្ចនិងទេសចរណ៍

-អគ្គនាយកដ្ឋានកិច្ចការសង្គម

-អគ្គនាយកដ្ឋានផលិតកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់

-អគ្គនាយកដ្ឋានរាជកិច្ចនិងតម្កល់ឯកសារជាតិ

៣-នាយកដ្ឋានសវនកម្មផ្ទៃក្នុង

៤-រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងអង្គភាពចំណុះទីស្តីការគណៈរដ្ឋមន្ត្រី។

## ១.២-រាជរដ្ឋាភិបាល (ត)

### +ក្រសួង និងរដ្ឋលេខាធិការដ្ឋាន

- ការបង្កើតក្រសួង ត្រូវកំណត់ដោយច្បាប់។ ជាគោលការណ៍ ក្រសួងជាស្ថាប័នរបស់រាជរដ្ឋាភិបាល ដែលត្រូវបង្កើតឡើង ដើម្បីទទួលបន្ទុកការងារតាមវិស័យ។
- ចំពោះ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ត្រូវបានកំណត់ឲ្យស្ថិតនៅក្រោមចំណុះទីស្តីការគណៈរដ្ឋមន្ត្រី ក្រោមការគ្រប់គ្រងរបស់នាយករដ្ឋមន្ត្រី។

-ក្រសួងត្រូវដឹកនាំដោយរដ្ឋមន្ត្រី១រូប និងមានរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការមួយចំនួនតាមការចាំបាច់ ដែលត្រូវបំពេញភារកិច្ចតាមការប្រគល់ពីរដ្ឋមន្ត្រីសាមី។

-ក្រសួងនីមួយៗមានរដ្ឋលេខាធិការប្រចាំការ១(មួយ)រូប ដែលចាត់តាំងដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីនៃក្រសួងសាមី ដើម្បីជួយការងារទូទៅប្រចាំថ្ងៃរបស់ក្រសួង។

## ១.២-រាជរដ្ឋាភិបាល (ត)

- រដ្ឋមន្ត្រី មានសមត្ថកិច្ចមួយចំនួន ដូចជា៖

-ចេញប្រកាស សេចក្តីសម្រេច សារាចរ និងសេចក្តីណែនាំ។

-ដឹកនាំការងារក្នុងក្រសួង និងគ្រប់គ្រងមន្ត្រីរាជការ បុគ្គលិក ដែលជាភ្នាក់ងាររដ្ឋបាលនៅក្រោមឱវាទរបស់ខ្លួន។

-លើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទ ចាប់ពីថ្នាក់ប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែលឡើងទៅ និងថ្នាក់វរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទនិងនគរបាលជាតិ។

-តែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការក្រោមឱវាទចាប់ពីថ្នាក់ក្រោមប្រធាននាយកដ្ឋាន និងថ្នាក់ប្រហាក់ប្រហែល និងថ្នាក់ក្រោមវរសេនីយ៍ឯកនៃកងយោធពលខេមរភូមិន្ទនិងនគរបាលជាតិ។

- **១.២-រាជរដ្ឋាភិបាល (ត)**
- បច្ចុប្បន្ន មានក្រសួងចំនួន២៧ ដូចជា៖

១-ក្រសួងមហាផ្ទៃ

២-ក្រសួងការពារជាតិ

៣-ក្រសួងទំនាក់ទំនងរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច

៤-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

៥-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

៦-ក្រសួងព័ត៌មាន

៧-ក្រសួងសុខាភិបាល

៨-ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

៩-ក្រសួងផែនការ

១០-ក្រសួងពាណិជ្ជកម្ម

១១-ក្រសួងអប់រំ យុវជន និងកីឡា

១២-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ១.២-រាជរដ្ឋាភិបាល (ត)

១៣-ក្រសួងបរិស្ថាន

១៤-ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

១៥-ក្រសួងអភិវឌ្ឍន៍ជនបទ

១៦-ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១៧-ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១៨-ក្រសួងធម្មការ និងសាសនា

១៩-ក្រសួងកិច្ចការនារី

២០-ក្រសួងសាធារណការ និងដឹកជញ្ជូន

២១-ក្រសួងយុត្តិធម៌

២២-ក្រសួងទេសចរណ៍

២៣-ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

២៤-ក្រសួងធនធានទឹក និងឧតុនិយម

២៥-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

២៦-ក្រសួងមុខងារសាធារណៈ

២៧-ក្រសួងរ៉ែ និងថាមពល។

- **១.២-រាជរដ្ឋាភិបាល (តចប់)**
- ក្រសួងនីមួយៗ ត្រូវមានរចនាសម្ព័ន្ធរដ្ឋបាលដូចខាងក្រោម៖

-ខុទ្ទកាល័យរបស់រដ្ឋមន្ត្រី ប្រធានស្ថាប័ន

-អង្គភាពកណ្តាលចំណុះឲ្យក្រសួង រួមមាន៖

.អគ្គលេខាធិការដ្ឋាន/អគ្គនាយកដ្ឋាន/អគ្គាធិការដ្ឋាន

.នាយកដ្ឋាន/អធិការដ្ឋាន

.ការិយាល័យ

.អង្គភាពថ្នាក់ក្រោមការិយាល័យ។

-គ្រឹះស្ថានសាធារណៈដែលស្ថិតនៅក្រោមអាណាព្យាបាល

-អង្គភាពមូលដ្ឋាន( ខាងក្រៅ ) ដោយនៅថ្នាក់រាជធានី ខេត្ត ហៅថា មន្ទីរ និង

នៅថ្នាក់ក្រុង ស្រុក ខណ្ឌ ហៅថា ការិយាល័យ។

- **២-រដ្ឋបាលថ្នាក់ក្រោមជាតិ (រដ្ឋបាលមូលដ្ឋាន)**
- តាមមាត្រា១៤៥ថ្មីនៃរដ្ឋធម្មនុញ្ញ ចែងថា ទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌចែងដូចខាងក្រោម៖

-មាត្រា៤. ភ្នំពេញ ជារាជធានីនៃព្រះរាជាណាចក្រកម្ពុជា។ រាជធានីភ្នំពេញចែកជាខណ្ឌ។ ខណ្ឌ ចែកជា សង្កាត់។

-មាត្រា៥. ខេត្ត ចែកជាក្រុង និងជាស្រុក។ ក្រុង ចែកជាសង្កាត់។ ស្រុក ចែកជាឃុំ និងជាសង្កាត់។

- រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ទាំងអស់ ត្រូវបានច្បាប់កំណត់ជានីតិបុគ្គលនៃនីតិសាធារណៈ។ នីតិបុគ្គលនីមួយៗ មានដែនដី ប្រជាពលរដ្ឋ និងមានក្រុមប្រឹក្សាមួយជាតំណាង។

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

- រាជធានី-ខេត្ត ជាថ្នាក់រដ្ឋបាលដែនដីមួយខ្ពស់បំផុត ដែលចំណុះឲ្យក្រសួងមហាផ្ទៃ និងជាតំណាងឲ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងមានវិសាលភាព និងសមត្ថកិច្ចលើវិស័យរដ្ឋបាលនិងនយោបាយ។
- ក្រុង-ស្រុក-ខណ្ឌ ជាថ្នាក់រដ្ឋបាលដែនដីបន្ទាប់ពីរាជធានី-ខេត្ត។
- រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

- **២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)**

### ២.១.១-អង្គការដឹកនាំរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

- ដើម្បីជានាការគ្រប់គ្រងនៅតាមដែនដីរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ គឺត្រូវបង្កើតឲ្យមានអង្គការដឹកនាំ ដូចជា៖ ក្រុមប្រឹក្សា និងគណៈអភិបាល។

**+ក្រុមប្រឹក្សា (អង្គនីតិប្បញ្ញត្តិ)**

- គឺជាអង្គការដែលមានអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ ដោយធ្វើឡើងនៅក្នុងអង្គប្រជុំ។
- វាត្រូវបង្កើតទ្បើងតាមរយៈការបោះឆ្នោតអសកល ដោយសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ជាអ្នកចូលរួមបោះឆ្នោតជ្រើសរើស សម្រាប់អាណត្តិ ៥ឆ្នាំ។

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

- សមាសភាពក្រុមប្រឹក្សា ត្រូវបានកំណត់ ដូចតទៅ៖

  -រាជធានី មិនឱ្យលើស២១រូប

  -ខេត្ត ចាប់ពី៩រូប ទៅ២១រូប

  -ក្រុង ចាប់ពី៧រូប ទៅ១៥រូប

  -ស្រុក ខណ្ឌ ចាប់ពី៧រូប ទៅ១៩រូប។

- សមាជិកក្រុមប្រឹក្សា ត្រូវបំពេញនូវលក្ខខណ្ឌ ដូចជា៖

  -មានសញ្ជាតិខ្មែរពីកំណើត

  -មានអាយុ២៥ឆ្នាំឡើងទៅ

  -មានសិទ្ធិបោះឆ្នោត

  -មានលក្ខណៈសម្បត្តិគ្រប់គ្រាន់។

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

- **តួនាទី និងសិទ្ធិអំណាចរបស់ក្រុមប្រឹក្សា៖** ជាតំណាងប្រជាពលរដ្ឋ ដែលទទួលខុសត្រូវក្នុងការគ្រប់គ្រងនិងចាត់ចែងរាល់កិច្ចការនានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយតម្លាភាព គណនេយ្យភាព សមធម៌និងបរិយាប័ន្ន ដើម្បីឆ្លើយតប និងបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ និងអភិវឌ្ឍមូលដ្ឋាន។ ដើម្បីសម្រេចបាននូវបេសកកម្មដ៏ចម្បងនេះ ក្រុមប្រឹក្សាត្រូវបានផ្តល់សិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងខាងប្រតិបត្តិ។
- ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិតាមរយៈការធ្វើដីការបស់ក្រុមប្រឹក្សា និងសិទ្ធិអំណាចប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេច ដែលធ្វើឡើងនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា។

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

- កិច្ចការដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ក្នុងការធ្វើសេចក្តីសម្រេចខាងបញ្ញត្តិនិងខាងប្រតិបត្តិនៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា មានដូចខាងក្រោម៖

-ការរៀបចំ ដើម្បីទទួលមុខងារ ភារកិច្ច និងធនធាន

-មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា

-មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា

-ផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគប្រចាំឆ្នាំ

-គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម

-បញ្ហាហិរញ្ញវត្ថុផ្សេងទៀត

-ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការ អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា

-ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ

-ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ។

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

+គណៈអភិបាល (អចិត្តពិសហាមជ្ឈការ)

- គឺជាអង្គការដែលមានអំណាចខាងប្រតិបត្តិនៅតាមដែនដីនីមួយៗ។
- វាកើតឡើងតាមរយៈការចាត់តាំង សម្រាប់អាណត្តិការងារមិនលើសពី៤ឆ្នាំ ហើយអាចត្រូវបានតែងតាំងបាន៤ឆ្នាំទៀត សម្រាប់អាណត្តិទី២ នៅក្នុងដែនសមត្ថកិច្ចដដែល។
- សមាសភាពគណៈអភិបាល ត្រូវបានកំណត់ ដូចតទៅ៖

- រាជធានីយ៉ាងច្រើន៧រូប និង ខេត្តចាប់ពី៣រូបទៅ៧រូប ដែលត្រូវបានចាត់តាំងជា៖

.អភិបាល (ឋានន្តរសក្តិជាឧត្តមមន្ត្រី, អាយុ៣៥ឆ្នាំឡើងទៅ និងមានបទពិសោធន៍ការងារ៧ឆ្នាំយ៉ាងតិច) និង

.អភិបាលរង (ឋានន្តរសក្តិជាវរៈមន្ត្រីឡើងទៅ, អាយុ៣៥ឆ្នាំឡើងទៅ និងមានបទពិសោធន៍ការងារ ៥ឆ្នាំយ៉ាងតិច)។

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

- ក្រុង ស្រុក ខណ្ឌ ចាប់ពី៣រូបទៅ៥រូប ដែលត្រូវបានចាត់តាំងជា៖

.អភិបាល (មានឋានន្តរសក្តិជាអនុមន្ត្រីឡើងទៅ, អាយុ៣០ឆ្នាំឡើងទៅ និងមានបទពិសោធន៍ការងារ ៥ឆ្នាំ យ៉ាងតិច)និង

.អភិបាលរង (មានឋានន្តរសក្តិជានាយក្រមការឡើងទៅ, អាយុ២៥ឆ្នាំ ឡើងទៅ និងមានបទពិសោធន៍ការងារ៣ឆ្នាំយ៉ាងតិច)។

- ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)
- តួនាទី ភារកិច្ចរបស់គណៈអភិបាល រួមមាន៖

-ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីផ្តល់យោបល់ជូនក្រុមប្រឹក្សាអំពីកិច្ចការនានា ដែលពាក់ព័ន្ធនឹងសិទ្ធិអំណាចខាងបញ្ញត្តិនិងសិទ្ធិអំណាចខាងប្រតិបត្តិ ដើម្បីក្រុមប្រឹក្សាធ្វើការពិភាក្សាអនុម័តក្នុងកិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញទាក់ទងនឹង៖

.ការពិនិត្យមុខងារ ភារកិច្ច និងធនធានទាំងអស់ ដែលបានប្រគល់ ឬបានផ្ទេរមកឲ្យក្រុមប្រឹក្សា និងអំពីរបៀបរបប បែបបទ និតិវិធីនៃការអនុវត្តមុខងារ ភារកិច្ចនិងការចាត់ចែងធនធានទាំងនោះ

.ការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធនិងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធាន ដែលបានប្រគល់ ឬបានផ្ទេរ

.ផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំ

.ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ

.គម្រោងថវិកាប្រចាំឆ្នាំ

.ការបង្កើត ការកែសម្រួល ឬការរំសាយទីចាត់ការ ឬការិយាល័យ

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

.ការរៀបចំតួនាទី ភារកិច្ច និងលក្ខខណ្ឌការងាររបស់បុគ្គលិក

.ការតែងតាំង ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក

.ការកំណត់លក្ខណៈសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្សនិងកម្រៃផ្សេងៗ នៃបុគ្គលិករបស់ក្រុមប្រឹក្សា

.ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់ទីចាត់ការ និងបុគ្គលិករបស់ក្រុមប្រឹក្សា

.ការកំណត់យុទ្ធសាស្ត្រអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិករបស់ក្រុមប្រឹក្សា

.ការបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារតាមការចាំបាច់ ដើម្បីជួយដល់ការអនុវត្តការងាររបស់ក្រុមប្រឹក្សា

.ការរៀបចំយុទ្ធសាស្ត្រផ្សព្វផ្សាយព័ត៌មានដល់សាធារណជន ដូចជា៖ ការរៀបចំក្តារព័ត៌មាន, ការបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងការស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ច

.កិច្ចការផ្សេងៗទៀត ដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា និងដែលតម្រូវដោយក្រុមប្រឹក្សារបស់ខ្លួន។

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

-ក្រៅពីបំពេញតួនាទីក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន អភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ជាតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល ក្នុងការណែនាំ សម្របសម្រួល តម្រង់ទិសដល់មន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួងស្ថាប័ននានា និងទីភ្នាក់ងារនានារបស់រាជរដ្ឋាភិបាល ដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

ជាមួយគ្នានេះ អភិបាលត្រូវធ្វើជាតំណាងរាជរដ្ឋាភិបាល និងក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការងារសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

### ២.១.២-រចនាសម្ព័ន្ធរដ្ឋបាលរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

- នៅតាមរាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌនីមួយៗ បានកំណត់ឲ្យមានទីតាំងនៃអគាររដ្ឋបាលរបស់ខ្លួន ដូចជា៖

-សាលារាជធានីភ្នំពេញ

-សាលាខេត្ត

-សាលាក្រុង

-សាលាស្រុក

-សាលាខណ្ឌ។

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

**+សាលារាជធានីភ្នំពេញ៖** គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សានិងគណៈអភិបាលរាជធានីភ្នំពេញ។

- វាត្រូវបានកំណត់ឲ្យមានរចនាសម្ព័ន្ធចំណុះ ដូចជា៖ នាយករដ្ឋបាលសាលារាជធានី និងអង្គភាពមួយចំនួន រួមមាន៖

-ទីចាត់ការរដ្ឋបាល
-ទីចាត់ការផែនការ និងវិនិយោគ
-ទីចាត់ការហិរញ្ញវត្ថុ
-ទីចាត់ការរៀបចំក្រុង
-ទីចាត់ការគ្រប់គ្រងធនធានមនុស្ស
-ទីចាត់ការអន្តរវិស័យ
-ទីចាត់ការកិច្ចការច្បាប់ និងសិទ្ធិមនុស្ស
-ទីចាត់ការកិច្ចការគ្រប់គ្រងកាកសំណល់
-អង្គភាពលទ្ធកម្ម។

**+បង្កើតបន្ថែម៖**
-ទីចាត់ការទំនាក់ទំនងអន្តរជាតិ
-អង្គភាពច្រកចេញចូលតែមួយ
+ផ្អែកតាមការចាំបាច់ ក៏បានបង្កើតឲ្យមាន **ការិយាល័យប្រជាពលរដ្ឋ** ដែលជាយន្តការអព្យាក្រឹត សម្រាប់ទទួលនិងសម្រុះសម្រួលដោះស្រាយបណ្តឹងពាក់ព័ន្ធសេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាល។

## ២.១- រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

- ទីចាត់ការនីមួយៗ ត្រូវមានការិយាល័យចំណុះដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន១រូប និងមានអនុប្រធានយ៉ាងច្រើន២រូបជាជំនួយការ។
- របៀបរបបការងារ ត្រូវបានកំណត់ដូចខាងក្រោម៖

-ប្រធានការិយាល័យនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយកទីចាត់ការរបស់ខ្លួន និងនាយករដ្ឋបាលសាលារាជធានី។

-នាយកទីចាត់ការនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលារាជធានី។

-នាយករដ្ឋបាលសាលារាជធានី ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន។

# រដ្ឋបាលរាជធានី



## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

+**សាលាខេត្ត៖** គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត។

- វាត្រូវបានកំណត់ឲ្យមានរចនាសម្ព័ន្ធចំណុះ ដូចជា៖ នាយករដ្ឋបាលសាលាខេត្ត និងអង្គភាពមួយចំនួន រួមមាន៖

  -ទីចាត់ការរដ្ឋបាល

  -ទីចាត់ការផែនការ និងវិនិយោគ

  -ទីចាត់ការហិរញ្ញវត្ថុ

  -ទីចាត់ការគ្រប់គ្រងធនធានមនុស្ស

  -ទីចាត់ការអន្តរវិស័យ

  -អង្គភាពលទ្ធកម្ម។

**+បង្កើតបន្ថែម៖**

-អង្គភាពច្រកចេញចូលតែមួយ

+ផ្អែកតាមការចាំបាច់ ក៏បានបង្កើតឲ្យមាន **ការិយាល័យប្រជាពលរដ្ឋ** ដែលជាយន្តការអព្យាក្រឹត សម្រាប់ទទួលនិងសម្រុះសម្រួល ដោះស្រាយបណ្តឹងពាក់ព័ន្ធសេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាល។

- **២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)**
- ទីចាត់ការនីមួយៗ ត្រូវមានការិយាល័យចំណុះដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន១រូប និងមានអនុប្រធានយ៉ាងច្រើន២រូបជាជំនួយការ។
- របៀបរបបការងារ ត្រូវបានកំណត់ដូចខាងក្រោម៖

-ប្រធានការិយាល័យនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយកទីចាត់ការរបស់ខ្លួន និងនាយករដ្ឋបាលសាលាខេត្ត។

-នាយកទីចាត់ការនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាខេត្ត។

-នាយករដ្ឋបាលសាលាខេត្ត ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន។

# រដ្ឋបាលខេត្ត



ក្រុមប្រឹក្សា
គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
គណៈកម្មាធិការផ្សេងទៀត
មន្ទីរ អង្គភាពជំនាញ
គណៈអភិបាល
នាយករដ្ឋបាល
ទីចាត់ការ រដ្ឋបាល
ទីចាត់ការ ផែនការ និង វិនិយោគ
ទីចាត់ការ ហិរញ្ញវត្ថុ
ទីចាត់ការ គ្រប់គ្រងធនធានមនុស្ស
ទីចាត់ការ អន្តរវិស័យ
អង្គភាពលទ្ធកម្ម
ការិ. រដ្ឋបាល និង ឯកសារ
ការិ. ទំនាក់ទំនងសាធារណៈ និង សហប្រតិបត្តិការអន្តរជាតិ
ការិ. សរុប និង ព័ត៌មាន
ការិ. ស្ថិតិ អត្រានុកូលដ្ឋាន
ការិ. លេខាធិការក្រុមប្រឹក្សា
ការិ. វិនិយោគ
ការិ. ផែនការ
ការិ. គាំទ្រឃុំសង្កាត់
ការិ. ហិរញ្ញកិច្ច
ការិ. គណនេយ្យ
ការិ. គ្រប់គ្រងទ្រព្យសម្បត្តិ
ការិ. គ្រប់គ្រងបុគ្គលិក
ការិ. កសាងសមត្ថភាព
ការិ. កិច្ចការសេដ្ឋកិច្ច និងសង្គមកិច្ច
ការិ. គ្រប់គ្រងការអភិវឌ្ឍ និងសំណង់
ការិ. កិច្ចការច្បាប់ និងសុវត្ថិភាពសាធារណៈ

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

+**សាលាក្រុង៖** គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សានិងគណៈអភិបាលក្រុង។

- វាត្រូវបានកំណត់ឲ្យមានរចនាសម្ព័ន្ធចំណុះ ដូចជា៖ នាយករដ្ឋបាលសាលាក្រុង និង អង្គភាពមួយចំនួនដូចជា៖

  -ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

  -ការិយាល័យផែនការ និងគាំទ្រសង្កាត់

  -ការិយាល័យអភិវឌ្ឍក្រុង

  -អង្គភាពលទ្ធកម្ម។

**+បង្កើតបន្ថែម៖**
-ការិយាល័យច្រកចេញចូលតែមួយ
+ផ្អែកតាមការចាំបាច់ ក៏បានបង្កើតឲ្យមាន **ការិយាល័យប្រជាពលរដ្ឋ** ដែលជាយន្តការ អព្យាក្រឹត សម្រាប់ទទួល និងសម្រុះសម្រួល ដោះស្រាយបណ្ដឹងពាក់ព័ន្ធសេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាល។

-ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន១រូប និងមានអនុប្រធាន១រូបជាជំនួយការ។

-ប្រធានការិយាល័យនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះ នាយករដ្ឋបាលសាលាក្រុង។ នាយករដ្ឋបាលសាលាក្រុង ត្រូវមានការទទួលខុសត្រូវ និង គណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន។

# រដ្ឋបាលក្រុង


ក្រុមប្រឹក្សា
គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និង កុមារ
ការិយាល័យជំនាញ
គណៈអភិបាល
នាយករដ្ឋបាល
ការិយាល័យ
ផែនការ និងគាំទ្រឃុំសង្កាត់
ការងារផែនការ
ការិយាល័យ
រដ្ឋបាល និងហិរញ្ញវត្ថុ
ពិធីការ
លេខាធិការក្រុមប្រឹក្សា
ការិយាល័យ
អភិវឌ្ឍក្រុង
កិច្ចការអភិវឌ្ឍក្រុង
អង្គភាពលទ្ធកម្ម

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

+**សាលាស្រុក៖** គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សានិងគណៈអភិបាលស្រុក។

- វាត្រូវបានកំណត់ឲ្យមានរចនាសម្ព័ន្ធចំណុះ ដូចជា៖ នាយករដ្ឋបាលសាលាស្រុក និងអង្គភាពមួយចំនួនដូចជា៖

  -ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

  -ការិយាល័យផែនការ និងគាំទ្រឃុំសង្កាត់

  -ការិយាល័យអន្តរវិស័យ

  -អង្គភាពលទ្ធកម្ម។

+**បង្កើតបន្ថែម៖**
-ការិយាល័យច្រកចេញចូលតែមួយ
+ផ្អែកតាមការចាំបាច់ ក៏បានបង្កើតឲ្យមាន **ការិយាល័យប្រជាពលរដ្ឋ** ដែលជាយន្តការអព្យាក្រឹត សម្រាប់ទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងពាក់ព័ន្ធសេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាល។

- ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន១រូប និងមានអនុប្រធាន១រូបជាជំនួយការ។

-ប្រធានការិយាល័យនីមួយៗ ត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាស្រុក។ នាយករដ្ឋបាលសាលាស្រុក ត្រូវមានការទទួលខុសត្រូវ និងគណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន។

# រដ្ឋបាលស្រុក



## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (ត)

+**សាលាខណ្ឌ៖** គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សានិងគណៈអភិបាលខណ្ឌ។

- វាត្រូវបានកំណត់ឲ្យមានរចនាសម្ព័ន្ធចំណុះ ដូចជា៖ នាយករដ្ឋបាលសាលាខណ្ឌ និង អង្គភាពមួយចំនួនដូចជា៖

  -ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

  -ការិយាល័យផែនការ និងអភិវឌ្ឍ

  -ការិយាល័យអន្តរវិស័យ

  -អង្គភាពលទ្ធកម្ម។

**+បង្កើតបន្ថែម៖**
-ការិយាល័យច្រកចេញចូលតែមួយ
+ផ្អែកតាមការចាំបាច់ ក៏បានបង្កើតឲ្យមាន **ការិយាល័យប្រជាពលរដ្ឋ** ដែលជាយន្តការ អព្យាក្រឹត សម្រាប់ទទួល និងសម្រុះសម្រួល ដោះស្រាយបណ្ដឹងពាក់ព័ន្ធសេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាល។

-ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន១រូប និងមានអនុប្រធាន១រូបជាជំនួយការ។

-ប្រធានការិយាល័យនីមួយៗត្រូវទទួលខុសត្រូវ និងមានគណនេយ្យភាពដោយផ្ទាល់ចំពោះ នាយករដ្ឋបាលសាលាខណ្ឌ។ នាយករដ្ឋបាលសាលាខណ្ឌ ត្រូវមានការទទួលខុសត្រូវ និង គណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន។

# រដ្ឋបាលខណ្ឌ


ក្រុមប្រឹក្សា
គណៈកម្មាធិការលទ្ធកម្ម
គណៈកម្មាធិការផ្សេងទៀត
គណៈអភិបាល
នាយករដ្ឋបាល
អង្គភាពលទ្ធកម្ម

## ២.១-រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ (តចប់)

### ២.១-៣-ហិរញ្ញវត្ថុរបស់រាជធានី ខេត្ត និងក្រុង ស្រុក ខណ្ឌ

- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រង់មាត្រា២៤៤ បានកំណត់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុផ្ទាល់ខ្លួន ដែលបានមកពីចំណូល ដូចជា៖

-ចំណូលពីប្រភពនៅមូលដ្ឋាន រួមមាន៖ ពន្ធនៅមូលដ្ឋាន, ឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត, អំណោយស្ម័គ្រចិត្ត និងប្រភពផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬអនុក្រឹត្យ។

-ចំណូលពីថ្នាក់ជាតិ រួមមាន៖ ចំណូលចែករំលែក, មូលនិធិផ្ទេរពីថវិការដ្ឋ និងថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារ ដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួងស្ថាប័ន។

## ២-២-ឃុំ-សង្កាត់

- ឃុំ-សង្កាត់ជាថ្នាក់រដ្ឋបាលដែនដីទាបបំផុតរបស់ព្រះរាជាណាចក្រកម្ពុជា ដើម្បីជានាការគ្រប់គ្រងកិច្ចការមូលដ្ឋានក្នុងដែនដីរបស់ខ្លួន។
- ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមនយោបាយវិមជ្ឈការ។
- ដើម្បីជានាលើការគ្រប់គ្រងតាមនយោបាយវិមជ្ឈការគឺឃុំសង្កាត់នីមួយៗ ត្រូវបានកំណត់ឲ្យមាន៖

  -រចនាសម្ព័ន្ធរដ្ឋបាលឃុំ-សង្កាត់

  -ហិរញ្ញវត្ថុរបស់ឃុំ-សង្កាត់។

## ២.២-ឃុំ-សង្កាត់ (ត)

### ២.២.១-រចនាសម្ព័ន្ធរដ្ឋបាលឃុំ-សង្កាត់

- ការផ្តល់អំណាចដឹកនាំ និងការគ្រប់គ្រងឃុំ-សង្កាត់បានមកដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ ដោយសំងាត់ ក្នុងក្របខ័ណ្ឌនៃឃុំ-សង្កាត់នីមួយៗ។
- នៅតាមឃុំ-សង្កាត់នីមួយៗ ត្រូវបានកំណត់នូវរចនាសម្ព័ន្ធរដ្ឋបាល ដូចជា៖
  - ក្រុមប្រឹក្សាឃុំ-សង្កាត់
  - មេឃុំ-ចៅសង្កាត់
  - ជំទប់-ចៅសង្កាត់រង
  - ស្មៀនឃុំ-សង្កាត់។

# រដ្ឋបាលឃុំ-សង្កាត់


ក្រុមប្រឹក្សាឃុំ សង្កាត់
មេឃុំ ចៅសង្កាត់
ជំទប់ទី១ ចៅសង្កាត់រងទី១
ជំទប់ទី២ ចៅសង្កាត់រងទី២
គណៈកម្មាធិការ
គណៈកម្មាធិការ
គណៈកម្មាធិការ
គណៈកម្មាធិការ
ស្មៀន និងបុគ្គលិកឃុំ សង្កាត់
ភូមិ
ភូមិ
ភូមិ
ភូមិ
ភូមិ

## ២.២-ឃុំ-សង្កាត់ (ត)

### +ក្រុមប្រឹក្សាឃុំ-សង្កាត់

- គឺជាអង្គការ ដែលមានអំណាចបញ្ញត្តិក្នុងក្របខ័ណ្ឌឃុំ-សង្កាត់នីមួយៗ។
- វាត្រូវបានបង្កើតឡើងដោយការបោះឆ្នោត ហើយដែលមានអាណត្តិ៥ឆ្នាំ ឬផុតកំណត់នៅពេលដែលមានក្រុមប្រឹក្សាឃុំ-សង្កាត់ថ្មីចូលកាន់តំណែង។
- ក្រុមប្រឹក្សានេះត្រូវមានសមាជិកពី ៥រូបទៅ១១រូប ដោយផ្អែកទៅតាមចំនួនប្រជាសាស្ត្រ និងភូមិសាស្ត្ររបស់ខ្លួន (ចំនួនជាក់ស្តែងនឹងត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។
- សមាសភាពនីមួយៗនៃក្រុមប្រឹក្សាឃុំ-សង្កាត់សុទ្ធតែជាសមាជិក សមាជិកានៃគណបក្សនយោបាយ។

## ២.២-ឃុំ-សង្កាត់ (ត)

- ប្រជាពលរដ្ឋទាំងពីរភេទដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

-មានសញ្ជាតិខ្មែរពីកំណើត

-ចេះអាន និងសរសេរអក្សរខ្មែរ

-បានចុះឈ្មោះក្នុងបញ្ជីឈ្មោះអ្នកបោះឆ្នោតក្នុងឃុំ-សង្កាត់ ដែលខ្លួនមានបំណងឈរឈ្មោះ។

-មានអាយុយ៉ាងតិច ២៥ឆ្នាំ គិតមកទល់ថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់។

-មានលក្ខណៈសម្បត្តិគ្រប់គ្រាន់តាមល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់។

## ២.២-ឃុំ-សង្កាត់ (ត)

- អំណាចសំខាន់ៗ របស់ក្រុមប្រឹក្សាឃុំ-សង្កាត់ រួមមាន៖

  -ការអនុម័តលើគម្រោងថវិកាឃុំ-សង្កាត់។

  -ការកំណត់តម្លៃសារពើពន្ធមូលដ្ឋាន មិនមែនសារពើពន្ធ និងកម្រៃសេវាផ្សេងៗ។

  -ការបោះឆ្នោតអនុម័តបទបញ្ញាផ្ទៃក្នុង និងដីកាឃុំ-សង្កាត់។

  -ការអនុម័តលើគម្រោងផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់។

  -សម្រេចកិច្ចការផ្សេងៗទៀត ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

- ចំពោះបញ្ហាខាងលើនេះ ក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវធ្វើការបោះឆ្នោតអនុម័តដោយសំលេងភាគច្រើនដាច់ខាត នៃសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងមូល។

## ២.២-ឃុំ-សង្កាត់ (ត)

### +មេឃុំ-ចៅសង្កាត់

- គឺជាបុគ្គលដែលមានអំណាចប្រតិបត្តិនៅតាមឃុំសង្កាត់នីមួយៗ និងជាប្រធានក្រុមប្រឹក្សាឃុំ-សង្កាត់។
- មេឃុំ-ចៅសង្កាត់ មានតួនាទីនិងភាកិច្ច ដូចតទៅ៖

-ធ្វើជាអធិបតីក្នុងសម័យប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ-សង្កាត់របស់ខ្លួន។

-អនុវត្តសេចក្តីសម្រេច បទបញ្ជា និងគោលការណ៍នានា ដែលបានទទួលពីក្រុមប្រឹក្សាឃុំ-សង្កាត់។

-ជានាឱ្យមានកិច្ចប្រជុំក្រុមប្រឹក្សាឃុំ-សង្កាត់យ៉ាងតិច មួយដងក្នុង១ខែ ដើម្បីធ្វើសេចក្តីរាយការណ៍អំពី សកម្មភាពការងារជូនក្រុមប្រឹក្សា និងផ្តល់យោបល់ដល់ក្រុមប្រឹក្សាក្នុងការរៀបចំផែនការហិរញ្ញវត្ថុក្នុងការអនុវត្ត ការងារ។

-រក្សារបៀបរៀបរយ និងសណ្តាប់ធ្នាប់ក្នុងពេលប្រជុំ។

## ២.២-ឃុំ-សង្កាត់ ( ត )

### +ជំទប់-ចៅសង្កាត់រង

- គឺជាបុគ្គលដែលទទួលបន្ទុកជាជំនួយការរបស់មេឃុំ-ចៅសង្កាត់ ក្នុងការអនុវត្តន៍ភារកិច្ចដែលមេឃុំ-ចៅសង្កាត់ប្រគល់ឲ្យនិងជំនួសមេឃុំ-ចៅសង្កាត់ទៅតាមឋានានុក្រមនៅពេលដែលមេឃុំ-ចៅសង្កាត់អវត្តមាន។

-ជំទប់ទី១-ចៅសង្កាត់រងទី១ មានភារកិច្ចជួយមេឃុំ-ចៅសង្កាត់លើកិច្ចការសេដ្ឋកិច្ច ហិរញ្ញវត្ថុ។

-ជំទប់ទី២-ចៅសង្កាត់រងទី២ មានភារកិច្ចជួយមេឃុំ-ចៅសង្កាត់លើកិច្ចការរដ្ឋបាល សង្គមកិច្ច សេវាសាធារណៈ និងសណ្តាប់ធ្នាប់សាធារណៈ។

## ២.២-ឃុំ-សង្កាត់ (ត)

**+ស្មៀនឃុំ-សង្កាត់**

- គឺជាបុគ្គលិកក្របខ័ណ្ឌក្រសួងមហាផ្ទៃ ត្រូវបានចាត់តាំងដើម្បីជួយកិច្ចការឃុំ-សង្កាត់ និងជានានិរន្តរភាពកិច្ចការរដ្ឋបាលឃុំ-សង្កាត់។
- ស្មៀនឃុំ-សង្កាត់ មានភារកិច្ចដូចខាងក្រោម៖

-កត់ត្រា និងថែរក្សាការពារទ្រព្យសម្បត្តិសាធារណៈនិងទ្រព្យសម្បត្តិឯកជន

-ជួយមេឃុំ-ចៅសង្កាត់ក្នុងកិច្ចការរដ្ឋបាលឃុំ-សង្កាត់

-ធ្វើជាសេនាធិការឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់និងតំណាងឱ្យក្រុមប្រឹក្សាក្នុងការធ្វើសេចក្ដីសម្រេច និងអនុវត្តសេចក្ដីសម្រេចនានា។

- ស្មៀនឃុំ-សង្កាត់ ត្រូវផ្លាស់ប្ដូរក្នុងករណីមានសំណើរបស់មេឃុំ-ចៅសង្កាត់ អនុលោមតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់។

## ២.២-ឃុំ-សង្កាត់ (ត)

+មេភូមិ

- ក្នុងគោលដៅលើកកំពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងឃុំ-សង្កាត់ គឺក្រុមប្រឹក្សាឃុំ-សង្កាត់ត្រូវរៀបចំជ្រើសរើសឲ្យមានមេភូមិម្នាក់សំរាប់ភូមិនីមួយៗតាមរយៈការបោះឆ្នោត ដើម្បីចំណុះឃុំ-សង្កាត់របស់ខ្លួន។ មេភូមិត្រូវរៀបចំចាត់តាំងឱ្យមានអនុប្រធានភូមិ១រូប និងជំនួយការមេភូមិ១ចំនួន ដើម្បីឱ្យក្រុមប្រឹក្សាឃុំ-សង្កាត់អនុម័តយល់ព្រមដោយលើកដៃតាមសំលេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់។
- ជារួម មេភូមិ មានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

-អនុវត្តនូវភារកិច្ចដែលក្រុមប្រឹក្សាឃុំ-សង្កាត់ ឬមេឃុំ-ចៅសង្កាត់ ប្រគល់ឱ្យដើម្បីជានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមក្នុងភូមិ។

-ផ្តល់យោបល់ដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ អំពីបញ្ហានានាដែលទាក់ទងដល់ផលប្រយោជន៍ក្នុងភូមិរបស់ខ្លួន។

-ស្នើសុំយោបល់ទៅក្រុមប្រឹក្សាឃុំ-សង្កាត់ ឬមេឃុំ-ចៅសង្កាត់ ដើម្បីចាត់ចែង និងសម្របសម្រួលកិច្ចការនៅក្នុងភូមិរបស់ខ្លួន។

- ## ២.២-ឃុំ-សង្កាត់ (ត)

### ២. ២.២-ហិរញ្ញវត្ថុរបស់ឃុំ-សង្កាត់

- តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ-សង្កាត់ ត្រង់មាត្រា៧៣ ចែងថា ឃុំ-សង្កាត់មានធនធានហិរញ្ញវត្ថុ ថវិកានិងទ្រព្យសម្បត្តិផ្ទាល់ខ្លួន។ ធនធានទាំងនោះបានមកពី៖

-ចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធ និងកំរៃសេវាផ្សេងៗ ដោយរាប់បញ្ចូលទាំងពន្ធលើអចលនទ្រព្យ និងការជួលផ្សេងៗ។

-ទទួលបាននូវធនធានវិភាជន៍ពីចំណូលរដ្ឋសម្រាប់ថវិកាឃុំ-សង្កាត់ និងការធ្វើវិភាជន៍នូវចំណែកដ៏ជាក់លាក់នៃប្រាក់ចំណូលរដ្ឋពីថវិការដ្ឋប្រចាំឆ្នាំដែលត្រូវបើកនូវរតនាគាររាជធានី- ខេត្ត។

-មានទទួលប្រាក់កំរៃចំពោះការអនុវត្តនូវតួនាទីជាភ្នាក់ងារតំណាងឱ្យរដ្ឋ ដែលរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នណាមួយនៃរាជរដ្ឋាភិបាលបានប្រគល់ឱ្យអនុវត្ត។

-អនុប្បទាន និងការខ្ចីពីប្រភពក្នុងប្រទេស និងក្រៅប្រទេស តាមរយៈរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ បើពុំនោះទេ ឃុំ-សង្កាត់គ្មានសិទ្ធិខ្ចីប្រាក់ ឬ ធានារ៉ាប់រងចំពោះការខ្ចីប្រាក់ឡើយ។

- ហិរញ្ញវត្ថុរបស់ឃុំ-សង្កាត់ ត្រូវតែមានការរៀបចំ និងអនុម័តដោយក្រុមប្រឹក្សាឃុំ-សង្កាត់ជារៀងរាល់ឆ្នាំ។

## ២.២-ឃុំ-សង្កាត់ ( តចប់ )

**សម្គាល់៖**

តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល ឃុំ សង្កាត់ ត្រង់មាត្រា៤៥ ចែងថា រដ្ឋបាលឃុំ-សង្កាត់ គ្មានអំណាចសម្រេចលើវិស័យទាំងឡាយដូចជា៖

-ព្រៃឈើ

-ប្រៃសណីយ៍និងទូរគមនាគមន៍

-ការពារប្រទេស

-សន្តិសុខជាតិ

-រូបិយវត្ថុ

-នយោបាយក្រៅប្រទេស

-គោលនយោបាយសារពើពន្ធ

-និងវិស័យផ្សេងៗទៀត ដែលមានចែងនៅក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធ។

# មេរៀនទី៤
# គ្រឹះស្ថានសាធារណៈ

- **១-សញ្ញាណទូទៅនៃគ្រឹះស្ថានសាធារណៈ**

  **+អត្ថន័យ**

- គ្រឹះស្ថានសាធារណៈ ជានីតិបុគ្គលនៃនីតិសាធារណៈដែលទទួលបន្ទុកអនុវត្តសកម្មភាពណាមួយ ដើម្បីបម្រើប្រយោជន៍ទូទៅ។

  **+ លក្ខណៈវិនិច្ឆ័យ**

  -នីតិបុគ្គលនៃនីតិសាធារណៈ

  -មានបេតិកភណ្ឌ និងស្វ័យភាព

  -ឯកទេសកម្ម

  -នៅក្រោមអាណាព្យាបាលរដ្ឋ ឬ សមូហភាពដែនដី

- **២-ប្រភេទគ្រឹះស្ថានសាធារណៈ**
- ជាគោលការណ៍ គ្រឹះស្ថានសាធារណៈត្រូវបានកំណត់ជា ២ប្រភេទដូចខាងក្រោម៖

  -គ្រឹះស្ថានសាធារណៈរដ្ឋបាល

  -គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច។

## ២.១-គ្រឹះស្ថានសាធារណៈរដ្ឋបាល

### + អត្ថន័យ

- គ្រឹះស្ថានសាធារណៈរដ្ឋបាល គឺជានីតិបុគ្គលនៃនីតិសាធារណៈដែលទទួលបន្ទុកចម្បងនូវបេសកកម្មផ្នែកសេវាសាធារណៈ ជាអាទិ៍៖ សេវាមានលក្ខណៈរដ្ឋបាល សង្គមកិច្ចសុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រ ឬ បច្ចេកទេស។
- គ្រឹះស្ថានសាធារណៈនេះ ត្រូវមានលក្ខណៈសម្បត្តិ ដូចជា៖ នាមករណ៍, ទីស្នាក់ការ, កម្មវត្ថុ, ក្រុមប្រឹក្សាភិបាល និងអង្គភាពប្រតិបត្តិ, ថវិកាផ្ទាល់, ទ្រព្យសម្បត្តិសម្រាប់ធ្វើសកម្មភាព, សមត្ថភាពចុះកិច្ចសន្យានិងប្តឹង ឬការពារនៅតុលាការ, ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនិងរដ្ឋប្បវេណីលើទង្វើរបស់អ្នកតំណាងស្របច្បាប់ ឬ និយោជិតរបស់ខ្លួន ដែលបានប្រព្រឹត្តក្នុងក្របខ័ណ្ឌនៃការបំពេញមុខងារជូនគ្រឹះស្ថានសាធារណៈ។
- គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវបង្កើតឡើងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ តាមសំណើរួមរបស់ក្រសួង ស្ថាប័នអាណាព្យាបាលបច្ចេកទេស និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ២.១-គ្រឹះស្ថានសាធារណៈរដ្ឋបាល (ត)

### +ក្រុមប្រឹក្សាភិបាល

- គ្រឹះស្ថានសាធារណៈរដ្ឋបាលត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលជាអង្គការដឹកនាំខ្ពស់បំផុត និងមានបេសកកម្មតម្រង់ទិសដៅការអនុវត្តនិងត្រួតពិនិត្យសកម្មភាពការងាររបស់គ្រឹះស្ថាន។
- វាត្រូវមានសមាជិកយ៉ាងតិច៥រូប យ៉ាងច្រើន៩រូប ក្នុងករណីចាំបាច់អាចបន្ថែមដល់ ១១រូប ដែលក្នុងនោះត្រូវមាន៖

  - តំណាងក្រសួងស្ថាប័នអាណាព្យាបាលបច្ចេកទេស
  - តំណាងក្រសួងអាណាព្យាបាលហិរញ្ញវត្ថុ
  - តំណាងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀត។

  នាយកនៃគ្រឹះស្ថាន គឺជាសមាជិកក្រុមប្រឹក្សាភិបាល។

  ក្រុមប្រឹក្សាភិបាលមានតំណាងបុគ្គលិករបស់គ្រឹះស្ថាន១រូប ជាសមាជិកស្វ័យប្រវត្តិ ដែលជ្រើសរើសដោយបុគ្គលិកក្នុងចំណោមបុគ្គលិករបស់គ្រឹះស្ថានសម្រាប់អាណត្តិ៣ឆ្នាំ។

## ២.១-គ្រឹះស្ថានសាធារណៈរដ្ឋបាល (ត)

- បេក្ខភាពជាសមាជិកក្រុមប្រឹក្សាភិបាលត្រូវបានជ្រើសរើស ដោយផ្អែកតាមលក្ខណៈសម្បត្តិនិងបទពិសោធន៍ដូចជា៖មានសញ្ជាតិខ្មែរ, បម្រើការងារយ៉ាងតិច៥ឆ្នាំ, ពុំធ្លាប់ទទួលការផ្តន្ទាទោសពីបទមជ្ឈិមឬឧក្រិដ្ឋ, មានសមត្ថភាពជំនាញនៅក្នុងវិស័យពាក់ព័ន្ធជាអាទិ៍ រដ្ឋបាល សង្គមកិច្ច សុខាភិបាល វប្បធម៌ អប់រំ វិទ្យាសាស្ត្រនិងបច្ចេកទេស។
- ប្រធាននិងសមាជិកក្រុមប្រឹក្សាភិបាលត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ **៣ឆ្នាំ**។
- លើកលែងតែប្រធានក្រុមប្រឹក្សាភិបាល មុខងារជាសមាជិកក្រុមប្រឹក្សាភិបាលមានវិសមិតភាពជាមួយនឹងមុខងារជាសមាជិករាជរដ្ឋាភិបាល, សមាជិករដ្ឋសភា និងសមាជិកព្រឹទ្ធសភា។

## ២.១-គ្រឹះស្ថានសាធារណៈរដ្ឋបាល (តចប់)

**+អង្គភាពប្រតិបត្តិ**

- គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវមាននាយកគ្រឹះស្ថាន ដែលដឹកនាំនិងគ្រប់គ្រងអង្គភាពប្រតិបត្តិ។
- នាយកគ្រឹះស្ថាន ត្រូវតែងតាំង និងបញ្ចប់ពីតំណែងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រី ឬដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងស្ថាប័នអាណាព្យាបាលបច្ចេកទេស។
- មុខងារជានាយកគ្រឹះស្ថានមានវិសមិតភាពជាមួយនឹងមុខងារជាសមាជិករាជរដ្ឋាភិបាល, សមាជិករដ្ឋសភា, សមាជិកព្រឹទ្ធសភា និងជាមួយប្រធានក្រុមប្រឹក្សាភិបាល។

## ២.២-គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច

+អត្ថន័យ

- គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច គឺជានីតិបុគ្គលនៃនីតិសាធារណៈ ដែលទទួលបន្ទុកសេវាសាធារណៈមានលក្ខណៈឧស្សាហកម្ម និងពាណិជ្ជកម្ម សម្រាប់បំពេញតម្រូវការទីផ្សារ។
- គ្រឹះស្ថាននេះត្រូវមានលក្ខណៈសម្បត្តិដូចជា៖ នាមករណ៍, ទីស្នាក់ការ, កម្មវត្ថុ, ក្រុមប្រឹក្សាភិបាល និងការគ្រប់គ្រងដោយឡែក, ថវិកាផ្ទាល់, ទ្រព្យសម្បត្តិសម្រាប់ធ្វើសកម្មភាពដូចមានគ្រោងទុកក្នុងកម្មវត្ថុរបស់ខ្លួន, សមត្ថភាពចុះកិច្ចសន្យា និងអាចការពារនៅចំពោះមុខតុលាការ, ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនិងរដ្ឋប្បវេណីលើទង្វើរបស់តំណាងស្របច្បាប់ ឬនិយោជិតរបស់ខ្លួនក្នុងពេលបំពេញការងារជូនគ្រឹះស្ថាន។

## ២.២-គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច (ត)

### +ក្រុមប្រឹក្សាភិបាល

- ក្រុមប្រឹក្សាភិបាល ជាអង្គការដឹកនាំខ្ពស់បំផុតនៅក្នុងគ្រឹះស្ថាន និងបំពេញមុខងារប្រកប ដោយស្វ័យភាពបរិបូរណ៍។
- វាត្រូវមានសមាជិកមិនលើសពី០៧រូប។ បុគ្គលិករបស់គ្រឹះស្ថានសាធារណៈត្រូវមានអសនៈមួយសម្រាប់ជាតំណាងនិយោជិត ហើយត្រូវបានបោះឆ្នោតជ្រើសតាំងពីនិយោជិតនៃគ្រឹះស្ថានសាធារណៈនោះ។
- សមាជិកក្រុមប្រឹក្សាភិបាលទាំងឡាយត្រូវបានជ្រើសរើសដោយផ្អែកតាមលក្ខណៈសម្បត្តិ និងបទពិសោធន៍របស់ខ្លួន ឬមួយក្នុងចំណោមមន្ត្រីរាជការបំរើការងារយ៉ាងតិច៥ឆ្នាំ ឬចូលនិវត្តន៍តែមានអាយុមិនលើស៦៥ឆ្នាំ ឬមួយក្នុងចំណោមឥស្សរជនដែលមានសមត្ថភាពខាងសេដ្ឋកិច្ច នីតិសាស្ត្រ និងវិទ្យាសាស្ត្រ។

## ២.២-គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច (ត)

- សមាជិកក្រុមប្រឹក្សាភិបាលមានវិសមិតភាពជាមួយមុខងារជាសមាជិករដ្ឋសភា ឬសមាជិក រាជរដ្ឋាភិបាល។
- គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ត្រូវស្ថិតក្រោមអាណាព្យាបាលបច្ចេកទេសនៃក្រសួង ឬអាជ្ញាធរសាធារណៈណាមួយ អាស្រ័យទៅលើប្រភេទនៃសកម្មភាពរបស់ខ្លួន។
- គ្រឹះស្ថាននេះ ត្រូវបានកំណត់ក្នុងការត្រួតពិនិត្យដូចជា៖
  - ការត្រួតពិនិត្យរបស់រដ្ឋ
  - ការត្រួតពិនិត្យហិរញ្ញវត្ថុ និងអធិការកិច្ចរបស់ក្រសួងពាក់ព័ន្ធ។

## ២.២-គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច (តចប់)

- គ្រឹះស្ថានសាធារណៈមានលក្ខណៈសេដ្ឋកិច្ច ត្រូវបានដឹកនាំដោយប្រធានអគ្គនាយក១រូប ដែលជាប្រធានក្រុមប្រឹក្សាភិបាលផងនិងជាអគ្គនាយកផងដែរ ហើយដែលបំពេញមុខងារក្រោមការត្រួតពិនិត្យរបស់ក្រុមប្រឹក្សាភិបាល។
- តួនាទីរបស់ប្រធានក្រុមប្រឹក្សាភិបាលនិងអគ្គនាយកអាចញែកចេញពីគ្នាបាន។ ក្នុងករណីនេះ ទីចាត់ការប្រតិបត្តិនៃគ្រឹះស្ថានត្រូវដឹកនាំដោយអគ្គនាយក។
- ប្រធានអគ្គនាយក ឬ អគ្គនាយកត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងអាណាព្យាបាល ឬ អាជ្ញាធរអាណាព្យាលនៃគ្រឹះស្ថាននោះ។
- ចំពោះសមាជិកដទៃទៀតនៃក្រុមប្រឹក្សាភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់ក្រសួង ឬអាជ្ញាធរ ដែលសមាជិកនោះជាតំណាងនិងការជ្រើសរើសក្នុងល័ក្ខខ័ណ្ឌជាកំណត់។

# សូមអរគុណ